# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចកែសម្រួលលើកទី៤
# លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០១៩ ឯអ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០២
# សម្រាប់លោក តែ កុកអេង
# អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ០១៩ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក តែ កុកអេង នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០២
- យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយរបស់លោក តែ កុកអេង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៧
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ១១៥ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០១៩ឯអ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០២ ដែលបានផ្តល់ជូនលោក **តែ កុកអេង** (បន្ទាប់ពីនេះហៅថា**"អ្នកកាន់អាជ្ញាប័ណ្ណ"**) សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ ចែកចាយអគ្គិសនី ដែលមានស្រាប់ (មានបង្ហាញក្នុងផែនទីភ្ជាប់លេខ 019LD-map- Te Kok Eng-Revised-1-2007 ) ។

### ប្រការ២

ឧបសម្ព័ន្ធទី១ចាស់ នៃឯកសារអាជ្ញាប័ណ្ណលេខ ០១៩ ឯអ ត្រូវជំនួសដោយ ឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

### ប្រការ៣

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណ លេខ ០១៩ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៤**

សេចក្ដីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០១៩ ឯអ ។

**ប្រការ៥**

សេចក្ដីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្ដីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០១៩ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០១៩ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្ដីសម្រេចនេះ ។

ភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី ១១៥ នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧

១- តំបន់អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺនៅទីប្រជុំជនឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ " ផែនទីកំណត់ព្រំ ប្រទល់លេខ 019LD-map-Te Kok Eng-Revised-1-2007 " ដែលភ្ជាប់ មកជាមួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ មានបំណងស្នើសុំពង្រីកតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសំរេចអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយ ណាមួយ ឧបសម្ព័ន្ធទី១ នេះត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកតំបន់ចែកចាយនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។